ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ុំ គិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ុំ ប៊ុលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុកន្ទួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ គិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មានន្ទ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួរ
២៣-មេធាវី អ៊ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ: ០៣១ /គ.ម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៦-២០២០

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៧
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥

## ស ម្រេ ច

**ប្រការ ១.-** ត្រូវបានដាក់ឱ្យអនុវត្ត "ផែនការយុទ្ធសាស្ត្រនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៦-២០២០" ដូចមានចែងក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។



អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

**ប្រការ ២.-** សេចក្តីសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

**ចម្លងជូន:**

-ក្រុមប្រឹក្សាគណៈមេធាវី

-ឯកសារ-កាលប្បវត្តិ

មេធាវី. ប៊ុន_ហុន

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៣១ សសគម/១៦ ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៦

# ផែនការយុទ្ធសាស្ត្រនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
## ឆ្នាំ ២០១៦ - ២០២០

| លទ្ធផល | ទិន្នផល | សកម្មភាព | ហានិភ័យ |
|---|---|---|---|
| **គោលដៅយុទ្ធសាស្ត្រទី ១៖ លើកកម្ពស់ការគោរពនិងការពារសិទ្ធិមនុស្សនិងនីតិរដ្ឋតាមរយៈប្រព័ន្ធតុលាការ** | | | |
| **លទ្ធផល៖**<br>• សិទ្ធិទទួលបានយុត្តិធម៌ត្រូវបានលើកស្ទួយនៅក្នុងនីតិវិធីតុលាការ | **ទិន្នផល៖**<br>• គោលនយោបាយនៃការផ្តល់សេវាកម្មច្បាប់ដល់ជនក្រីក្រត្រូវបានបង្កើត<br>• ទំព័រប្រព័ន្ធព័ត៌មានសង្គមត្រូវបានបង្កើត<br>• របាយការណ៍ពីចំនួននៃការផ្សព្វផ្សាយតាមទូរទស្សន៍/វិទ្យុ<br>• ការបោះពុម្ពផ្សាយអំពីបញ្ហានានានៅក្នុងវិស័យយុត្តិធម៌<br>• គោលនយោបាយនៃការអប់រំបន្តសំរាប់មេធាវីត្រូវបានបង្កើត<br><br>**សូចនាករណ៍៖**<br>• គោលនយោបាយផ្តល់សេវាកម្មច្បាប់សម្រាប់ជនក្រីក្រត្រូវបានបោះផ្សាយដល់សាធារណជនតាមគេហទំព័រ ឬ ប្រព័ន្ធព័ត៌មានសង្គម<br>• ចំនួនចូលមើលក្នុងគេហទំព័រ និង/ឬ ប្រព័ន្ធព័ត៌មានសង្គម<br>• ចំនួនមេធាវីដែលចូលរួមក្នុងវគ្គអប់រំបន្ត<br>• ចំនួនរឿងក្តីជនក្រីក្រដែលត្រូវបានការពារ<br><br>**មធ្យោបាយផ្ទៀងផ្ទាត់៖**<br>• របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍ដែលបោះផ្សាយលើគេហទំព័រ/ប្រព័ន្ធព័ត៌មានសង្គម | **សកម្មភាពទីមួយ៖** *ពង្រឹង និងពង្រីកសេវាផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ*<br><br>**កិច្ចការលំអិត៖**<br>• ធានាការផ្តល់សេវាការពារជូនជនក្រីក្រនៅទូទាំងប្រទេស។<br>• ប្រមូលស្ថិតិ/ទិន្នន័យតម្រូវការផ្នែកច្បាប់នៅទូទាំងប្រទេស។<br>• កំណត់ចំនួនតម្រូវការមេធាវីនៅតាមបណ្តាខេត្ត-រាជធានី។<br>• កំណត់កាតព្វកិច្ចការពារក្តីជូនជនក្រីក្ររបស់មេធាវីជាសមាជិកគណៈមេធាវី<br>• ពង្រីកសេវាពិគ្រោះយោបល់ផ្នែកច្បាប់ដោយមិនគិតកម្រៃ<br>• កំណត់កាតព្វកិច្ចដល់សិស្សមេធាវីសម្រាប់ពិគ្រោះយោបល់ច្បាប់ដោយមិនគិតកម្រៃ<br>• រៀបចំកម្មវិធីមណ្ឌលច្បាប់ចល័ត ដើម្បីធ្វើការពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋាន<br>• រៀបចំកម្មវិធីផ្សព្វផ្សាយឱ្យសាធារណជនយល់ដឹងពីសេវាកម្មផ្តល់ជំនួយផ្នែកច្បាប់របស់គណៈមេធាវី( | **កត្តាហានិភ័យ៖**<br>• ការខ្វះខាតថវិកា<br>• ការខ្វះខាតមេធាវីស្ម័គ្រចិត្តចូលរួមអនុវត្តកិច្ចការដែលបានកំណត់<br>• កិច្ចសហការជាមួយស្ថាប័នសាធារណៈនៅពុំទាន់រឹងមាំ<br><br>**វិធីកាត់បន្ថយហានិភ័យ៖**<br>• ស្វែងរកថវិកាពីដៃគូសហការ/អភិវឌ្ឍន៍<br>• ជម្រុញឱ្យរាជរដ្ឋាភិបាលបន្ថែមថវិកាសម្រាប់ដំណើរការផ្តល់សេវាផ្នែកច្បាប់ដល់ជនក្រីក្រ<br>• ពង្រឹងកិច្ចសហការជាមួយស្ថាប័នសាធារណៈ។ |

| | | | |
|---|---|---|---|
| | | ឧ.ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសង្គម (social media), ព្រឹត្តិបត្រមេធាវី, ទូរទស្សន៍, វិទ្យុ)<br>• វិភាគចំណុចខ្លាំង/ចំណុចខ្សោយទាក់ទងនឹងសិទ្ធិទទួលបានយុត្តិធម៌ (ឧ.វិភាគសាលក្រម, រៀបចំទិន្នន័យនៃបញ្ហាលើកឡើងដោយមេធាវីទាក់ទងនឹងការធ្វើកិច្ចការនិងការអនុវត្តច្បាប់របស់តុលាការ) | |
| | **ទិន្នផលៈ**<br>• ទម្រង់នៃការវាយតម្លៃរបស់កូនក្តីចំពោះសេវាមេធាវីដែលការពារក្តីត្រូវបានបង្កើត<br>• របាយការណ៍របស់អ្នកពិគ្រោះឯករាជ្យស្តីពីការវាយតម្លៃនៃគុណភាពសេវាកម្មច្បាប់សម្រាប់ជនក្រីក្រ<br><br>**សូចនាករណ៍ៈ**<br>• របាយការណ៍របស់អ្នកពិគ្រោះឯករាជ្យស្តីពីការវាយតម្លៃនៃគុណភាពសេវាកម្មច្បាប់សម្រាប់ជនក្រីក្រ<br>• ចំនួនវគ្គបណ្តុះបណ្តាលមេធាវីជួយការពារក្តីជូនជនក្រីក្រ<br><br>**មធ្យោបាយផ្ទៀងផ្ទាត់ៈ**<br>• របាយការណ៍វាយតម្លៃ<br>• បញ្ជីវត្តមានមេធាវី<br>• របាយការណ៍ស្ថិតិនៃការចូលរួមក្នុងវគ្គបណ្តុះបណ្តាល | **សកម្មភាពទី ២ៈ** *បង្កើនគុណភាពនៃការផ្តល់សេវាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ*<br><br>**កិច្ចការលំអិតៈ**<br>• វាយតម្លៃអំពីការងាររបស់សមាជិកដែលផ្តល់សេវាកម្មច្បាប់សម្រាប់ជនក្រីក្រ (ឧ. បង្កើតទម្រង់សំណួរទាក់ទងនឹងការបំពេញការងារការពារក្តីដែលត្រូវឆ្លើយដោយមេធាវី, កូនក្តី, និងមន្ត្រីតុលាការ, ការវាយតម្លៃដោយអ្នកពិគ្រោះឯករាជ្យ)<br>• បណ្តុះបណ្តាលក្រុមមេធាវីដែលជាសមាជិកការពារក្តីជូនជនក្រីក្រ (ឧ.កម្មវិធីបណ្តុះបណ្តាលដែលផ្តល់ដោយអ្នកជំនាញជាក់លាក់លើប្រធានបទណាមួយ)<br>• បង្កើតកម្មវិធីលើកទឹកចិត្តដល់មេធាវីដែលបម្រើការងារដោយស្ម័គ្រចិត្តនៅនាយកដ្ឋានការពារក្តីជូនជនក្រីក្រ<br>• ស្វែងរក និងបង្កើនកិច្ចសហការល្អជាមួយក្រសួង ស្ថាប័ន អង្គការ សមាគម និងដៃគូនានា ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃសេវាកម្ម | **កត្តាហានិភ័យៈ**<br>• មេធាវីពាក់ព័ន្ធមិនពេញចិត្តឱ្យគេវាយតម្លៃ<br>• ការខ្វះខាតមេធាវីស្ម័គ្រចិត្តចូលរួមក្នុងការវិភាគ<br>• ការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលដែលរៀបចំដោយគណៈមេធាវីនៅមានកម្រិត<br><br>**វិធីកាត់បន្ថយហានិភ័យៈ**<br>• ការរៀបចំគោលនយោបាយដែលកំណត់ជាកាតព្វកិច្ចរបស់មេធាវី<br>• ការចាត់តាំងពីប្រធានគណៈមេធាវី |
| | **ទិន្នផលៈ**<br>• ក្រុមឯកទេសខាងគ្រប់គ្រងនិងសរសេរសំណើសុំជំនួយត្រូវបានបង្កើត | **សកម្មភាពទី៣** - *ស្វែងរក និងបង្កើនទំនាក់ទំនងជាមួយស្ថាប័នដែលមានគោលការណ៍ផ្តល់ថវិកាគាំទ្រដល់សេវាកម្មផ្នែកច្បាប់* | **កត្តាហានិភ័យៈ**<br>• ការខ្វះខាតមេធាវីស្ម័គ្រចិត្តចូលរួមក្នុងក្រុមវិភាគនិងសរសេរសំ |

| | | | |
|---|---|---|---|
| | **សូចនាករណ៍៖**<br>• ចំនួនសំណើសុំជំនួយដើម្បីគាំទ្រគំរោងសេវាកម្មច្បាប់ដល់ជនក្រីក្រ<br><br>**មធ្យោបាយផ្ទៀងផ្ទាត់៖**<br>• សេចក្តីសម្រេចតែងតាំងក្រុមឯកទេស<br>• សំណើនានាដែលដាក់ជូនម្ចាស់ជំនួយ (រាជរដ្ឋាភិបាល និង ម្ចាស់ជំនួយផ្សេងទៀត) | **កិច្ចការលំអិត៖**<br>• បង្កើតក្រុមឯកទេសខាងគ្រប់គ្រងគំរោងដើម្បីផ្សព្វផ្សាយអំពីសេវាកម្មច្បាប់សំរាប់ជនក្រីក្រនិងលើកគំរោង<br>• ជួបប្រជុំជាមួយសមាជិក ស្ថាប័នដែលមានគោលការណ៍ផ្តល់ថវិកាគាំទ្រដល់សេវាកម្មផ្នែកច្បាប់ដើម្បីបង្ហាញពីគម្រោង និងផែនការសកម្មភាពរបស់គណៈមេធាវី ដើម្បីស្នើសុំការគាំទ្រថវិការ។ | ណើ/គម្រោង<br><br>**វិធីកាត់បន្ថយហានិភ័យ៖**<br>• ស្វែងរកកិច្ចសហការពីអង្គការ ឬសមាគមនានា ដែលមានជំនាញ ខាងសរសេរសំណើ/គម្រោង |
| **គោលដៅយុទ្ធសាស្ត្រទី ២៖ ការបង្កើនគុណភាព និងសមត្ថភាពរបស់មេធាវី** | | | |
| **លទ្ធផល៖**<br>• សមត្ថភាពបច្ចេកទេសការងាររបស់មេធាវីត្រូវបានពង្រឹង<br>• មេធាវីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារអាស៊ាន | **ទិន្នផល៖**<br>• វគ្គបណ្តុះបណ្តាលមុខវិជ្ជាជំនាញត្រូវបានរៀបចំ<br>• ដៃគូសហការត្រូវបានបង្កើត<br><br>**សូចនាករណ៍៖**<br>• ចំនួនវគ្គបណ្តុះបណ្តាលមុខវិជ្ជាជំនាញ<br>• ចំនួនអនុស្សារណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ<br><br>**មធ្យោបាយផ្ទៀងផ្ទាត់៖**<br>• របាយការណ៍ពីវគ្គជំនាញនានា<br>• អនុស្សារណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ | **សកម្មភាពទី១ - *ផ្តល់ឱកាសឱ្យមេធាវីនិងភាពសម្បូណ៌បែបនៅក្នុងការទទួលបានចំណេះ និងជំនាញក្នុងវិស័យជាក់លាក់***<br><br>**កិច្ចការលំអិត៖**<br>• រៀបចំវគ្គបណ្តុះបណ្តាលដំបូងដល់សិស្សមេធាវី និងការអប់រំបន្តចំណេះដឹង និងជំនាញក្នុងការប្រកបវិជ្ជាជីវៈរបស់មេធាវី ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការរំពឹងទុករបស់សមាជិក។<br>• ចុះអនុស្សារណៈដើម្បីបង្កើតទំនាក់ទំនងខាងក្នុង និងខាងក្រៅជាមួយស្ថាប័នច្បាប់ និងគណៈមេធាវីដទៃទៀត ជាពិសេសទំនាក់ទំនងជាមួយអាស៊ាន។<br>• បង្កើតទំនាក់ទំនងការងារជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល មេធាវី សហគមន៍ ក្នុងគោលបំណងធ្វើជាដៃគូយុទ្ធសាស្ត្រ។ | **កត្តាហានិភ័យ៖**<br>• ខ្វះខាតការចូលរួមរបស់មេធាវី<br>• ខ្វះខាតថវិកាក្នុងការរៀបចំ<br>• ខ្វះខាតអ្នកជំនាញក្នុងវិស័យទៅតាមតម្រូវការ<br><br>**វិធីកាត់បន្ថយហានិភ័យ៖**<br>• កំណត់ជាកាតព្វកិច្ចក្នុងការចូលរួម។<br>• ស្វែងរកដៃគូសហការ និងជំនួយផ្នែកបច្ចេកទេស និងថវិកា។ |

<table>
<tr>
<td></td>
<td>ទិន្នផលៈ<br>• ក្រុមការងាររៀបចំកម្មវិធីសិក្សាអំពីអាស៊ានត្រូវបានបង្កើត<br>• កម្មវិធីសិក្សាអំពីអាស៊ានត្រូវបានបញ្ជ្រាបក្នុងការអប់រំច្បាប់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី និង ក្នុងកម្មវិធីអប់រំច្បាប់បន្ត<br><br>សូចនាករណ៍ៈ<br>• ចំនួនវគ្គ និងចំនួនសិស្សមេធាវី និង មេធាវីបានទទួលការសិក្សាពីកម្មវិធីនេះ<br>• ចំនួនសិស្សមេធាវី/មេធាវីដែលបានទទួលវិញ្ញាបនបត្របញ្ចប់ការសិក្សាអំពីអាស៊ាន<br><br>មធ្យោបាយផ្ទៀងផ្ទាត់ៈ<br>• លិខិតតែងតាំង និងបញ្ជីឈ្មោះក្រុមការងារ<br>• កម្មវិធីសិក្សាត្រូវបានផ្សព្វផ្សាយ<br>• របាយការណ៍ពីវគ្គសិក្សានានា និង បញ្ជីវត្តមានកម្មសិក្សាការី</td>
<td>សកម្មភាពទី ២ - បង្កើនសមត្ថភាពមេធាវីក្នុងទិសដៅនៃសមាហរណកម្មអាស៊ាន<br><br>កិច្ចការលំអិតៈ<br>• បង្កើតក្រុមការងារដើម្បីរៀបចំកម្មវិធីសិក្សាអំពីទិដ្ឋភាពរួមរបស់អាស៊ាន<br>• បញ្ចូលក្នុងកម្មវិធីសិក្សាដើម្បីបង្កើនការយល់ដឹងពីរចនាសម្ព័ន្ធនយោបាយ និងសេដ្ឋកិច្ចអាស៊ាន កិច្ចព្រមព្រៀង/សន្ធិសញ្ញានានានៃអាស៊ាន និងប្រព័ន្ធច្បាប់នានានៃប្រទេសអាស៊ាន<br>• ចាត់ចែងរកអ្នកជំនាញខ្មែរ និងបរទេសដើម្បីបង្រៀនមុខវិជ្ជាអំពីអាស៊ាន<br>• លើកទឹកចិត្តឱ្យមេធាវីពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីប្រកួតប្រជែងនៅក្នុងទីផ្សារអាស៊ាន</td>
<td>កត្តាហានិភ័យៈ<br>• ការខ្វះខាតមេធាវីស្ម័គ្រចិត្តនិងឯកទេសដើម្បីចូលរួមក្នុងក្រុមការងារ<br><br>វិធីកាត់បន្ថយហានិភ័យៈ<br>• បង្កើនភាពទាក់ទាញដល់មេធាវីពាក់ព័ន្ធនឹងសកម្មភាពរបស់អាស៊ាន។</td>
</tr>
<tr>
<td colspan="4">គោលដៅយុទ្ធសាស្ត្រទី ៣៖ លើកកម្ពស់កេរ្តិ៍ឈ្មោះ និងកិត្យានុភាពរបស់គណៈមេធាវី</td>
</tr>
<tr>
<td>លទ្ធផលៈ<br>• សកម្មភាពរបស់គណៈមេធាវីត្រូវបានផ្សព្វផ្សាយ<br>• សាធារណជនស្គាល់គណៈមេធាវី និងសកម្មភាពរបស់គណៈមេធាវី</td>
<td>ទិន្នផលៈ<br>• របាយការណ៍ស្តីពីសេចក្តីត្រូវការច្បាប់ត្រូវបានផលិត<br><br>សូចនាករណ៍ៈ<br>• សេចក្តីសម្រេចទទួលយក/កែប្រែរបាយការណ៍ស្តីពីការសិក្សាប្រមាណមើលសេចក្តីត្រូវការច្បាប់<br><br>មធ្យោបាយផ្ទៀងផ្ទាត់ៈ<br>• របាយការណ៍ស្តីពីការសិក្សាប្រមាណមើលសេចក្តីត្រូវការច្បាប់របស់អ្នកពិគ្រោះយោបល់</td>
<td>សកម្មភាពទី ១ -<br>សិក្សាពីសេចក្តីត្រូវការច្បាប់នៅកម្ពុជាទៅតាមលំដាប់អាទិភាពនៃសេចក្តីត្រូវការទាំងនោះ<br><br>កិច្ចការលំអិតៈ<br>• សហការណ៍ជាមួយដៃគូ (អង្គការសហប្រជាជាតិ, អង្គការអន្តរជាតិ) ដើម្បីរៀបចំផែនការសិក្សាប្រមាណមើលសេចក្តីត្រូវការច្បាប់ (legal needs assessment)<br>• ជ្រើសរើសអ្នកពិគ្រោះយោបល់ដើម្បីធ្វើការសិក្សាដោយរួមជា</td>
<td>កត្តាហានិភ័យៈ<br>• ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធដើម្បីផ្តល់ទិន្នន័យ<br><br>វិធីកាត់បន្ថយហានិភ័យៈ<br>• គណៈមេធាវីធ្វើការទំនាក់ទំនងសុំកិច្ចសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធ</td>
</tr>
</table>

| | | | |
|---|---|---|---|
| | • របាយការណ៍ចុងក្រោយស្តីពីការសិក្សាប្រមាណមើលសេចក្តីត្រូវការច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី។ | មួយមេធាវីដែលចាត់តាំងដោយគណៈមេធាវី<br>• អ្នកពិគ្រោះយោបល់ធ្វើការប្រមាណមើលសេចក្តីត្រូវការច្បាប់នៅកម្ពុជា និងធ្វើរបាយការណ៍ | |
| | **ទិន្នផល៖**<br>• ក្រុមការងារផ្នែករដ្ឋប្បវេណី, ព្រហ្មទណ្ឌ, ពាណិជ្ជកម្មត្រូវបានបង្កើត<br>• សមាជិកដែលមានជំនាញក្នុងផ្នែកនិមួយៗត្រូវបានជ្រើសរើស<br>**សូចនាករណ៍៖**<br>• កិច្ចប្រជុំរាយការណ៍ពីទិន្នន័យនៃផ្នែកនីមួយៗត្រូវបានរៀបចំប្រចាំត្រីមាស<br>• របាយការណ៍ស្តីពីអនុសាសន៍ដើម្បីកែលំអការអនុវត្តច្បាប់ត្រូវបានចេញប្រចាំត្រីមាស ឬ ប្រចាំឆ្នាំ<br><br>**មធ្យោបាយផ្ទៀងផ្ទាត់៖**<br>• កំណត់តែងតាំងសមាជិកក្រុមការងារ<br>• របាយការណ៍នៃកិច្ចប្រជុំផ្នែកនីមួយៗ<br>• របាយការណ៍អនុសាសន៍ផ្ញើទៅកាន់ស្ថាប័នដែលពាក់ព័ន្ធ | **សកម្មភាពទី ២-** *គណៈមេធាវីបង្កើតក្រុមការងារចំពោះកិច្ចដើម្បីប្រមូលទិន្នន័យស្តីពីបញ្ហានៃការអនុវត្តច្បាប់ក្នុងវិស័យណាមួយ ដូចជា រដ្ឋប្បវេណី និងពាណិជ្ជកម្ម ជាដើម*<br><br>**កិច្ចការលំអិត៖**<br>• ក្រុមការងារធ្វើកិច្ចការប្រមូលទិន្នន័យស្តីពីបញ្ហានៃការអនុវត្តពីមេធាវី និងសង្គមស៊ីវិលនានា<br>• ក្រុមការងាររៀបចំវេទិកាសន្ទនារវាងវិស័យឯកជន តុលាការ មន្ត្រីរាជការ និងមេធាវី ដើម្បីរករូបមន្ត ឬយុទ្ធសាស្ត្រណាមួយក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ | **គន្លាហានិភ័យ៖**<br>• នៅពេលបង្កើតបានហើយ ក្រុមការងារមិនដំណើរការ សមាជិកគ្មានការប្តេជ្ញាវិភាគទានពេលវេលាដើម្បីធ្វើឱ្យក្រុមការងារមានដំណើរការផ្តល់លទ្ធផល<br><br>**វិធីកាត់បន្ថយហានិភ័យ៖**<br>• ធ្វើការសំរាំងអ្នកដែលមានការប្តេជ្ញាចិត្ត<br>• កំណត់រូបមន្តនៃសេចក្តីតម្រូវការនៃចំនួនចូលរួមជាចាំបាច់របស់សមាជិក<br>• ផ្តល់ការលើកទឹកចិត្តតាមផ្លូវសម្ភារៈខ្លះ និង កិត្តិយសខ្លះ |
| | **ទិន្នផល៖**<br>• កម្មវិធីបណ្តុះបណ្តាលសិស្សមេធាវី និង មេធាវីត្រូវបានដាក់តែងឡើង<br>• គោលនយោបាយអប់រំច្បាប់បន្តត្រូវបានដាក់តែងឡើង | **សកម្មភាពទី ៣-** *រៀបចំកម្មវិធីបណ្តុះបណ្តាលទាន់សម័យដល់សិស្សមេធាវី និងកម្មវិធីអប់រំច្បាប់បន្តដល់មេធាវីកំពុងប្រកបវិជ្ជាជីវៈ* | **គន្លាហានិភ័យ៖**<br>• ខ្វះខាតអ្នកជំនាញក្នុងការរៀបចំកម្មវិធីសិក្សា |

<table>
<tr><td></td><td>
<ul>
<li>ក្រុមគ្រូបង្រៀនច្បាប់មួយក្រុមត្រូវបានជ្រើសរើសតាមរយៈការសំរាំងយកអ្នកមានសមត្ថភាព និង បទពិសោធន៍</li>
<li>សៀវភៅសិក្សាមុខវិជ្ជាច្បាប់ផ្សេងៗត្រូវបានបោះពុម្ព និងចែកចាយ</li>
</ul>
សូចនាករណ៍៖
<ul>
<li>គោលនយោបាយអប់រំច្បាប់បន្តត្រូវបានផ្សព្វផ្សាយ</li>
<li>ស្ថិតិនៃមេធាវីដែលបានចូលរួមក្នុងកម្មវិធីអប់រំច្បាប់បន្ត</li>
<li>របាយការណ៍ពីស្ថិតិមេធាវីដែលបានបញ្ចប់ដោយជោគជ័យនូវការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី</li>
<li>លក្ខណៈវិនិច្ឆ័យសំរាប់ការចូលធ្វើកម្មសិក្សា និងការបញ្ចប់កម្មសិក្សារបស់មេធាវីត្រូវបានបង្កើតឡើង</li>
<li>ចំនួនសៀវភៅមុខវិជ្ជាច្បាប់</li>
</ul>
មធ្យោបាយផ្ទៀងផ្ទាត់៖
<ul>
<li>សេចក្តីសម្រេចដាក់ឱ្យប្រើកម្មវិធីបណ្តុះបណ្តាលសិស្សមេធាវី និងមេធាវីត្រូវបានអនុម័ត</li>
<li>សេចក្តីសម្រេចដាក់ឱ្យប្រើគោលនយោបាយអប់រំច្បាប់បន្ត</li>
<li>សេចក្តីសម្រេចតែងតាំងក្រុមគ្រូបង្រៀនច្បាប់</li>
<li>របាយការណ៍ប្រចាំឆ្នាំ/ត្រីមាសស្តីការអប់រំបន្ត</li>
<li>សេចក្តីសម្រេចដាក់ឱ្យប្រើនូវលក្ខណៈវិនិច្ឆ័យសំរាប់ការចូលធ្វើកម្មសិក្សា និងការបញ្ចប់កម្មសិក្សារបស់មេធាវី</li>
<li>សៀវភៅមុខវិជ្ជាច្បាប់</li>
</ul>
</td><td>
កិច្ចការលំអិត៖
<ul>
<li>គណៈកម្មការរៀបចំកម្មវិធីបណ្តុះបណ្តាលត្រូវបានបង្កើតឡើងសំរាប់សិស្សមេធាវី និង មេធាវីកំពុងប្រកបវិជ្ជាជីវៈដោយផ្អែកលើលទ្ធផលនៃរបាយ-ការណ៍សិក្សាប្រមាណមើលសេចក្តីត្រូវការច្បាប់</li>
<li>រៀបចំគោលនយោបាយដែលតម្រូវឱ្យមេធាវីត្រូវចូលរួមក្នុងកម្មវិធីអប់រំច្បាប់បន្ត</li>
<li>រៀបចំការជ្រើសរើសតាមបែបប្រកួតប្រជែងនូវគ្រូបង្រៀនច្បាប់ ដើម្បីបង្រៀនមុខវិជ្ជាដែលចង្អុលបង្ហាញដោយរបាយការណ៍នៃការសិក្សាប្រមាណមើលសេចក្តីត្រូវការច្បាប់។</li>
<li>រៀបចំលក្ខណៈវិនិច្ឆ័យសំរាប់ការចូលធ្វើកម្មសិក្សា និងការបញ្ចប់កម្មសិក្សារបស់មេធាវី</li>
</ul>
</td><td>
<ul>
<li>ខ្វះខាតធនធានមនុស្ស និងធនធានថវិកាក្នុងការរៀបចំដំណើរការគណៈកម្មការ</li>
</ul>
វិធីកាត់បន្ថយហានិភ័យ៖
<ul>
<li>ស្វែងរកដៃគូសហការ</li>
<li>រៀបចំបង្កើតរចនាសម្ព័ន្ធនៅក្នុងគណៈមេធាវី ដើម្បីរៀបចំស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីសិក្សា</li>
</ul>
</td></tr>
<tr><td></td><td>
ទិន្នផល៖
<ul>
<li>ក្រុមអ្នកនិពន្ធស្នូល និង អ្នកនិពន្ធចំពោះកិច្ច (ម្តងម្កាល) ត្រូវបានបង្កើត</li>
</ul>
សូចនាករណ៍៖
<ul>
<li>ការចេញផ្សាយព្រឹត្តិបត្តិមេធាវីជារយៈទៀងទាត់ (ត្រីមាស)</li>
</ul>
</td><td>
សកម្មភាពទី ៤- លើកស្ទួយនិងការធ្វើឱ្យប្រសើរឡើងនូវការបោះពុម្ពផ្សាយរបស់គណៈមេធាវី
<br><br>
កិច្ចការលំអិត៖
<ul>
<li>បង្កើត, លើកទឹកចិត្ត និង ផ្តល់រង្វាន់(ជាសម្ភារៈ ឬជាកិត្តិយស ដូចជាការផ្តល់ប្រាក់រង្វាន់ខ្លះ ឬ ការ</li>
</ul>
</td><td>
កត្តាហានិភ័យ៖
<ul>
<li>ខ្វះខាតអ្នកដែលមានការប្តេជ្ញាលះបង់ពេលវេលាដើម្បីចូលរួមវិភាគទាន</li>
<li>ខ្វះខាតបំណិនក្នុងការសរសេរ</li>
</ul>
</td></tr>
</table>

| | | | |
|---|---|---|---|
| | **មធ្យោបាយផ្ទៀងផ្ទាត់៖**<br>• ច្បាប់ចេញផ្សាយទៀងទាត់ | ប្រគល់វិញ្ញាបនបត្រសរសើរ ឬការប្រកាសទទួលស្គាល់នៅក្នុងមហាសន្និបាតជាដើម) ដល់ក្រុមអ្នកនិពន្ធស្ម័គ្រចិត្តដែលរួមវិភាគទានអត្ថបទ, សំណេរដល់ព្រឹត្តិបត្តិមេធាវី (មានអ្នកនិពន្ធស្នូល/ជាប្រចាំ និង អ្នកនិពន្ធស្ម័គ្រចិត្តម្តងម្កាល)<br>• បោះផ្សាយព្រឹត្តិបត្រមេធាវី ជាពុម្ព និង តាមគេហទំព័រគណៈមេធាវី | **វិធីកាត់បន្ថយហានិភ័យ៖**<br>• ធ្វើការបណ្តុះបណ្តាលក្រុមអ្នកនិពន្ធស្នូល<br>• ផ្តល់ការលើកទឹកចិត្តតាមផ្លូវសម្ភារៈខ្លះ និង កិត្តិយសខ្លះ |
| **គោលដៅយុទ្ធសាស្ត្រទី ៤៖ ពង្រឹង និងពង្រីកកម្មវិធីអប់រំផ្សព្វផ្សាយច្បាប់ដល់សាធារណជន** | | | |
| **លទ្ធផល៖**<br>• សាធារណជនទទួលបានចំណេះដឹងផ្នែកច្បាប់កាន់តែច្រើនឡើងៗ | **ទិន្នផល៖**<br>• កម្មវិធីផ្សព្វផ្សាយសំរាប់សាធារណៈត្រូវបានបង្កើតតាមទូរទស្សន៍/វិទ្យុ/គេហទំព័រ/ប្រព័ន្ធព័ត៌មានសង្គម<br>• ក្រុមគ្រូបង្គោលត្រូវបានបង្កើតនិងបណ្តុះបណ្តាល<br>**សូចនាករណ៍៖**<br>• ចំនួនអប់រំផ្សព្វផ្សាយ<br>• ចំនួនគ្រូបង្គោល<br><br>**មធ្យោបាយផ្ទៀងផ្ទាត់៖**<br>• របាយការណ៍ស្តីពីការផ្សព្វផ្សាយ<br>• សេចក្តីសម្រេចតែងតាំងគ្រូបង្គោលនិងបញ្ជីឈ្មោះ | **សកម្មភាពទី១-** ពង្រឹង និងពង្រីកកម្មវិធីអប់រំដល់សាធារណៈតាមរយៈសិក្ខាសាលាឬកម្មវិធីបណ្តុះបណ្តាល នៅថ្នាក់ជាតិ ឬ ថ្នាក់សហគមន៍ ឬតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដែលអាចធ្វើទៅបាន<br>• បង្កើត និង អប់រំគ្រូបង្គោលដើម្បីអនុវត្តការអប់រំច្បាប់ដល់សហគមន៍<br>• បង្កើត និងបន្តការអប់រំផ្សព្វផ្សាយច្បាប់ថ្មីៗដែលសភាអនុម័តរួចហើយដល់សមាជិកគណៈមេធាវី។<br>• ពង្រីកកម្មវិធីអប់រំច្បាប់របស់គណៈមេធាវីតាមសាលាទូទៅ។<br>• បង្កើតកម្មវិធីអប់រំច្បាប់សហគមន៍របស់គណៈមេធាវីតាមសហគមន៍នានា។ | **កត្តាហានិភ័យ៖**<br>• ខ្វះខាតថវិកាដើម្បីដំណើរការកម្មវិធី<br>• ខ្វះមេធាវីស្ម័គ្រចិត្តជាគ្រូបង្គោល<br>**វិធីកាត់បន្ថយហានិភ័យ៖**<br>• បង្កើតគ្រឿងលើកទឹកចិត្ត |